**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០១៣...៣០០.ប្រ.ក

# ប្រកាស
# ស្តីពី
# លក្ខណៈសម្គាល់នៃធនប័ត្រអនុស្សាវរីយ៍ ប្រភេទ ២០០០ រៀល

អនុលោមតាមអនុក្រឹត្យលេខ ៥៩៨ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ស្តីពីការចេញផ្សាយធនប័ត្រអនុស្សាវរីយ៍ ប្រភេទ ២០០០រៀល ក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា សូមប្រកាសផ្សាយជាសាធារណៈនូវលក្ខណៈសំគាល់នៃធនប័ត្រអនុស្សាវរីយ៍នេះ មានដូចខាងក្រោម ៖

**ក- __លក្ខណៈទូទៅ__ ៖**

- ទំហំធនប័ត្រ ៖ បណ្តោយ ១៤៦ មម និងទទឹង ៦៨ មម
- ពណ៌ចម្បង គឺពណ៌បៃតង ពណ៌លឿងខ្ចី និងពណ៌ក្រមៅ

**ខ- __ផ្ទៃខាងមុខ__ ៖**

- **ផ្នែកកណ្តាល** ខាងស្តាំត្រូវបានរំលេចឡើងនូវ ព្រះឆាយាល័ក្ខណ៍មើលពីមុខបញ្ឈិតចំហៀងខាងឆ្វេងនៃអតីតព្រះមហាក្សត្រ **ព្រះបរមរតនកោដ្ឋ** និងមានចារឹកអក្សរ " **ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះបិតាឯករាជ្យជាតិ** " នៅពីក្រោម ខាងឆ្វេងមានលេខ "២០០០" នៅពីលើគេ បន្ទាប់មកគឺជាហត្ថលេខារបស់ទេសាភិបាលនិងអគ្គបេឡា ព្រមទាំងរូបភាពព្រះសង្ហារនៃព្រះរាជាណាចក្រកម្ពុជា និងនៅខាងក្រោមមានលេខ-មាលាដែលបោះពុម្ពដោយទឹកខ្មៅពណ៌ខ្មៅ រូបភាពនាគក្បាល ៥ ដែលយកគំរូតាមរូបចម្លាក់នៅវិមានឯករាជ និងអក្សរ " ពីរពាន់រៀល " ព្រមទាំងអក្សរ " អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់ " នៅគែមខាងក្រោមនោះ និងមានបន្ទះពណ៌ទឹកមាសអមសង្ខាងដោយបន្ទះពណ៌ផ្ទៃមេឃ ដែលមានទំហំសរុប ៨ មម កាត់ទទឹងក្រដាសប្រាក់ពីលើដល់ក្រោម ។
- **ផ្នែកខាងស្តាំ** ជ្រុងលើមានអក្សរ " ធនាគារជាតិនៃកម្ពុជា " ព្រមទាំងលេខ-មាលាដែលត្រូវបានបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហមនៅពីក្រោមនោះ និងជ្រុងខាងក្រោមមានលេខ " ២០០០ " និង " 2000 " នៅបន្ទាប់គ្នា ។
- **ផ្នែកខាងឆ្វេង** មានលេខ " 2000 " ព្រាលៗដែលត្រូវបានបោះពុម្ពតាមបន្ទាត់បញ្ឈរ និងមានផ្ទៃបោះពុម្ពពិសេសពណ៌ទឹកប្រាក់ទំហំ ១០ មម កាត់ទទឹងក្រដាសប្រាក់ពីលើដល់ក្រោម ។

ប្រអប់សំបុត្រលេខ ២៥, ឡូតិ៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**គ- <u>ផ្ទៃខាងខ្នង</u> ៖**

- **ផ្ទៃកកណ្តាល** ត្រូវបានរំលេចឡើងនូវរូបភាពឯកសារស្តីព្រះរាជបូជនីយកិច្ចនៃអតីត **ព្រះមហាវីរក្សត្រ ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន** ក្នុងការដឹកនាំចលនាតស៊ូទាមទារឯករាជ្យជាតិពីសំណាក់ពួកអាណានិគមនិយមបារាំង និងមានអក្សរ " ពីរពាន់រៀល " នៅពីក្រោមនោះ ។
- **ផ្ទៃកខាងស្តាំ** មានរូបភាពវិមានឯករាជ្យ និងមានលេខ " ២០០០ " នៅពីក្រោមនោះ ព្រមទាំងលេខ " 2000 " ដែលត្រូវបានបោះពុម្ពតាមបន្ទាត់បញ្ឈរ នៅជ្រុងខាងលើ ។
- **ផ្ទៃកខាងឆ្វេង** ខាងលើមានអក្សរ " ធនាគារជាតិនៃកម្ពុជា " នៅកណ្តាលមានចារឹកអក្សរ " អបអរសាទរខួបអនុស្សាវរីយ៍លើកទី ៦០ ទិវាបុណ្យឯករាជ្យជាតិ ( ៩ វិច្ឆិកា ១៩៥៣ - ៩ វិច្ឆិកា ២០១៣ ) " និងនៅខាងក្រោមមានលេខ " ២០០០ " ដែលមានលេខតូច " ២០១៣ " នៅពីលើនោះ ។

ចាប់ពីថ្ងៃចេញប្រកាសនេះតទៅ ធនប័ត្រអនុស្សាវរីយ៍ ប្រភេទ ២០០០ រៀលត្រូវបានដាក់ឲ្យធ្វើចរាចរទន្ទឹមគ្នាជាមួយនឹងធនប័ត្រជាតិប្រភេទផ្សេងៗទៀត ដែលត្រូវបានចេញផ្សាយកន្លងមក ។ សាធារណជនគ្រប់រូបត្រូវពិនិត្យ-សម្គាល់ធនប័ត្រថ្មីនេះឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការភ័ន្តច្រឡំ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣

**ទេសាភិបាល**

ជា.ចាន់តូ